ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 27

# របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក

## Consolidated and Separate Financial Statements

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ “**ឈ្នះ-ឈ្នះ**” របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា “**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**”, “**យុទ្ធសាស្ត្រត្រីកោណ**”, “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០**” និង “**យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨**” ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី “**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា** ” ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៚✿៛

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង “*ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម*” ត្រូវបានដាក់ឱ្យប្រើដោយប្រកាស*លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**ឋិ តាឃី**

## វិសាលភាព

១ ស្តង់ដារនេះ ត្រូវបានអនុវត្តក្នុងការរៀបចំ និងការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុរួម សម្រាប់ក្រុមសហគ្រាសដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនមេ។

២ ស្តង់ដារនេះមិនទាក់ទងនឹងវិធីសាស្ត្រគណនេយ្យ សម្រាប់ការរួមបញ្ចូលអាជីវ-កម្ម និងផលប៉ះពាល់លើការរួមគ្នា រួមបញ្ចូលមូលនិធិពាណិជ្ជកម្មកើតឡើងពីការរួមបញ្ចូលអាជីវកម្ម( សូមមើល ស.រ.ហ.អ.ក៣ ការរួមបញ្ចូលអាជីកម្ម)។

៣ ស្តង់ដារនេះ ត្រូវបានអនុវត្តចំពោះគណនេយ្យ សម្រាប់ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា និងញាតិសម្ពន្ធ នៅពេលសហគ្រាសជ្រើសរើសយក ឬត្រូវបានតម្រូវដោយអាជ្ញាធរក្នុងស្រុក ក្នុងការបង្ហាញរបាយការណ៍ដោយឡែក។

## និយមន័យ

៤ ពាក្យបច្ចេកទេស ត្រូវបានប្រើក្នុងស្តង់ដារនេះ មានអត្ថន័យជាក់លាក់ ដូចខាងក្រោម÷

*របាយការណ៍ហិរញ្ញវត្ថុរួម* គឺជារបាយការណ៍ហិរញ្ញវត្ថុដែលក្រុមហ៊ុនបាបង្ហាញជារបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសសេដ្ឋកិច្ចតែមួយ ។

*ការគ្រប់គ្រង* **គឺជាអំណាចក្នុងការគ្រប់គ្រងលើគោលនយោបាយហិរញ្ញវត្ថុ និង ប្រតិបត្តិការ នៃសហគ្រាសមួយ និងហិរញ្ញវត្ថុរបស់ អង្គភាពមួយ ដើម្បីទទួល បានអត្ថប្រយោជន៍ពីសកម្មភាព។**

*ក្រុម* **ភាគីក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ពន្ធទាំងអស់។**

*ភាគកម្មអប្បភាគ* **គឺជាដើមទុនក្នុងក្រុមហ៊ុនបុត្រ ដែលចូលរួមដោយផ្ទាល់ ឬ មិនផ្ទាល់ ទៅលើក្រុមហ៊ុនមេ។**

*ក្រុមហ៊ុនមេ* **គឺជាសហគ្រាសដែលមានក្រុមហ៊ុនបុត្រសម្ព័ន្ធមួយ ឬច្រើន ។**

*របាយការណ៍ហិរញ្ញវត្ថុដោយឡែក* **គឺត្រូវបានបង្ហាញដោយក្រុមហ៊ុនមេជាអ្នក វិនិយោគក្នុងញាតិសម្ពន្ធ ឬអ្នកចូលរួមទុន ក្នុងសហគ្រាសគ្រប់គ្រងរួមគ្នាដែល ការវិនិយោគ ត្រូវបានធ្វើគណនេយ្យកម្ម ដោយឈរលើមូលដ្ឋាននៃភាគកម្ម តាមដើមទុនដោយផ្ទាល់ជាជាងឈរលើមូលដ្ឋាននៃលទ្ធផលបានរាយការណ៍ និងទ្រព្យសកម្មសុទ្ធនៃអ្នកទទួលបានការវិនិយោគ។**

*ក្រុមហ៊ុនបុត្រសម្ពន្ធ* **គឺជាសហគ្រាសមួយរួមទាំងសហគ្រាសមិនបញ្ចូលគ្នាដូច ជាសហកម្មសិទ្ធិ ដែលគ្រប់គ្រងដោយសហគ្រាសមួយទៀត (ហៅថាក្រុមហ៊ុន មេ)។**

៥ ក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ពន្ធ អាចជាអ្នកវិនិយោគក្នុងនាមញាតិសម្ពន្ធ ឬជាអ្នកចូលរួមទុន ឬសហគ្រាសគ្រប់គ្រងរួមគ្នា។ ករណីនេះ របាយការណ៍ ហិរញ្ញវត្ថុរួម ត្រូវរៀបចំ និងបង្ហាញស្របតាមស្តង់ដារនេះនិងត្រូវរៀបចំស្រប អនុលោមតាមស្តង់ដារស.គ.អ.ក២៨ការវិនិយោគក្នុងញាតិសម្ពន្ធនិងស្តងដារ ស.គ.អ.ក ៣១ ភាគកម្មក្នុងក្រុមហ៊ុនរួមទុន។

៦ សម្រាប់សហគ្រាសដូចបានបរិយាយក្នុងកថាខណ្ឌ ៥ របាយការណ៍ហិរញ្ញវត្ថុ ដោយឡែក ដែលបានរៀបចំ និងបង្ហាញបន្ថែម ទៅលើរបាយការណ៍ហិរញ្ញ

វត្ថុ ដែលយោង តាមកថាខណ្ឌ ៥។ របាយការណ៍ហិរញ្ញវត្ថុដោយឡែក មិនចាំបាច់បន្ថែម ឬ អម របាយការណ៍ទាំងនោះទេ ។

៧ របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស ដែលគ្មានក្រុមហ៊ុនបុត្រសម្ពន្ធញាតិសម្ពន្ធ ឬភាគកម្មក្នុងសហគ្រាសគ្រប់គ្រងរួមគ្នា មិនអាចចាត់ថាជារបាយការណ៍ដោយឡែកបានទេ។

៨ ក្រុមហ៊ុនមេដែលត្រូវបានលើកលែង ស្របតាមកថាខណ្ឌ ១០ ពីការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម អាចបង្ហាញរបាយការណ៍ដោយឡែក ដែលជារបាយការណ៍ហិរញ្ញវត្ថុតែមួយគត់ របស់ក្រុមហ៊ុនមេ ។

## ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម

៩ ក្រុមហ៊ុនមេមួយ លើកលែងតែក្រុមហ៊ុនមេដូចបានបរិយាយក្នុងកថាខណ្ឌ១០ ត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ក្នុងនោះរួមបញ្ចូលការវិនិយោគរបស់ក្រុមហ៊ុនមេក្នុងក្រុមហ៊ុនបុត្រសម្ពន្ធស្របតាមស្តង់ដារនេះ ។

១០ ក្រុមហ៊ុនមេមិនចាំបាច់បង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុរួមឡើយ ប្រសិនបើ ÷

(ក) ក្រុមហ៊ុនមេដែលកាន់កាប់ក្រុមហ៊ុនបុត្រសម្ពន្ធទាំងស្រុងឬកាន់កាប់ក្រុមហ៊ុនបុត្រសម្ពន្ធមួយផ្នែក ដោយសហគ្រាសមួយផ្សេងទៀត ឬដោយម្ចាស់ភាគហ៊ុនដទៃទៀត រួមបញ្ចូលការ គ្មានសិទ្ធិក្នុងការបោះឆ្នោត ត្រូវបានគេជូនដំណឹង និងជំទាស់ក្រុមហ៊ុនមេ មិនចាំបាច់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួមឡើយ ។

(ខ) ឧបករណ៍បំណុល ឬមូលធនរបស់ក្រុមហ៊ុនមេ មិនត្រូវបានលក់ដូរក្នុងលើទីផ្សារសាធារណៈ(ទីផ្សារក្នុងស្រុក ឬបរទេស ឬទីផ្សាររំលងបញ្ជរ ក្នុងនោះរួមមាន ទីផ្សារក្នុងស្រុក និងតំបន់) ។

(គ) ក្រុមហ៊ុនមេ ដែលមិនរៀបចំឯកសារ និង មិនដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដាក់ជូនគណៈកម្មការមូលបត្រ ឬបញ្ញត្តិករផ្សេងទៀតសម្រាប់គោលបំណងនៃការបោះផ្សាយនូវប្រភេទឧបករណ៍ហិរញ្ញវត្ថុណាមួយនៅក្នុងទីផ្សារសាធារណៈ និង

(ឃ) ក្រុមហ៊ុនមេធំបំផុត ឬក្រុមហ៊ុនមេ កណ្តាលណាមួយ ដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម សម្រាប់សាធារណជនប្រើប្រាស់ ដែលស្របតាមរបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

១១ ក្រុមហ៊ុនមេ ដែលមានលក្ខណៈដូច កថាខណ្ឌ ១០ មិនអាចបង្ហាញរបាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបង្ហាញតែរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ហើយត្រូវអនុវត្តតាមកថាខណ្ឌ ៣៨-៤៣ ។

## វិសាលភាពនៃរបាយការណ៍ហិរញ្ញវត្ថុរួម

**១២ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ របស់ក្រុមហ៊ុនមេ ។***

* ប្រសិនបើការទិញក្រុមហ៊ុនបុត្រសម្ព័ន្ធគោរពបាននូវលក្ខខណ្ឌដែលត្រូវបានចាត់ថ្នាក់ទុកសម្រាប់លក់ស្រប តាម ស.រ.ហ.អ.ក ៥ ទ្រព្យសកម្មរយៈពេល

១៣ ការគ្រប់គ្រង ត្រូវបានសន្មត់ថាមាន នៅពេលក្រុមហ៊ុនមេកាន់កាប់ ដោយផ្ទាល់ ឬប្រយោល ទៅលើក្រុមហ៊ុនបុត្រសម្ពន្ធអំណាចបោះឆ្នោតច្រើនជាងពាក់កណ្តាលនៃសហគ្រាសមួយ លើកលែងតែក្នុងស្ថានភាពពិសេសខ្លះដែលអាចត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់ថា ភាពជាម្ចាស់ភាគហ៊ុនមិនអាចគ្រប់គ្រងបាន។ ការគ្រប់គ្រងអាចមាននៅពេលក្រុមហ៊ុនមេកាន់កាប់ពាក់កណ្តាល ឬតិចជាងនៃអំណាចបោះឆ្នោតរបស់សហគ្រាសមួយ នៅពេលដែលមាន ÷

(ក) អំណាចលើសពីពាក់កណ្តាល នៃសិទ្ធិបោះឆ្នោត តាមរយៈកិច្ចព្រមព្រៀងជាមួយនឹងវិនិយោគិន ផ្សេងទៀត

(ខ) អំណាច ដើម្បីគ្រប់គ្រងគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការរបស់សហគ្រាស ក្រោមលក្ខន្តិកៈ ឬកិច្ចព្រមព្រៀង

(គ) អំណាច ដើម្បីតែងតាំង ឬដកចេញ សមាសភាពសមាជិកភាគច្រើនរបស់ក្រុមប្រឹក្សាភិបាល ឬ សហគ្រាសគ្រប់គ្រង ប្រហាក់ប្រហែលនឹងការគ្រប់គ្រងសហគ្រាស ធ្វើឡើងតាមរយៈក្រុមប្រឹក្សាភិបាល ឬសហគ្រាសគ្រប់គ្រងនោះ

(ឃ) អំណាចគ្រប់គ្រាន់ ដើម្បីបោះឆ្នោតតាមចំនួនភាគច្រើនដាច់ខាត នៅពេលប្រជុំក្រុមប្រឹក្សាភិបាល ឬក៏សហគ្រាសគ្រប់គ្រង និងការគ្រប់គ្រងសហគ្រាសធ្វើឡើងតាមរយៈក្រុមប្រឹក្សាភិបាលឬសហគ្រាសគ្រប់គ្រងនោះ ។

---

វែង ទុកសម្រាប់លក់ និងប្រតិបត្តិការមិនបន្ត ត្រូវចាត់ទុកតាម ស.រ.ហ.អ.ក នោះ។

១៤ សហគ្រាសមួយដែលកាន់កាប់ភាគហ៊ុនមានធានាភាគហ៊ុនជម្រើសឧបករណ៍បំណុល ឬមូលធន ដែលត្រូវបានបំលែងទៅជា ភាគហ៊ុនធម្មតា ឬជាឧបករណ៍ប្រហាក់ប្រហែលដែលមានសក្តានុពល ប្រសិនបើថ្ងៃអនុវត្ត ឬបំលែងផ្តល់ឱ្យសហគ្រាសមានអំណាចបោះឆ្នោត ឬបន្ថយអំណាចបោះឆ្នោតរបស់ភាគីផ្សេងទៀត លើគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការនៃសហគ្រាសផ្សេងទៀត (សក្តានុពលសិទ្ធិបោះឆ្នោត)។ ការមាន និងផលប៉ះពាល់នៃសក្តានុពលសិទ្ធិបោះឆ្នោត ដែលបច្ចុប្បន្នអាចអនុវត្តបាន ឬបំលែងបានដោយរាប់បញ្ចូលទាំងសក្តានុពលសិទ្ធិបោះឆ្នោតកាន់កាប់ ដោយសហ-គ្រាសផ្សេងទៀត ត្រូវរាប់បញ្ចូលនៅពេលវាយតម្លៃពីសហគ្រាសមួយមានអំណាចក្នុងការគ្រប់គ្រង លើគោលនយោបាយហិរញ្ញវត្ថុ និងប្រតិបត្តិការនៃសហគ្រាសមួយផ្សេងទៀត។សក្តានុពលសិទ្ធិបោះឆ្នោតដែលបច្ចុប្បន្នមិនអាចអនុវត្តបាន ឬបំលែងបាននៅពេល ឧទាហរណ៍ មិនអាចត្រូវបានអនុវត្ត ឬបំលែងបាននៅពេល រហូតដល់ថ្ងៃអនាគត ឬរហូតដល់ថ្ងៃដែលប្រតិបត្តិការនោះកើតឡើងនាពេលអនាគត ។

១៥ ដើម្បីធ្វើការវាយតម្លៃ ពីសក្តានុពលសិទ្ធិបោះឆ្នោតដែលចាត់ទុកថាជាការគ្រប់គ្រង សហគ្រាសត្រូវពិនិត្យគ្រប់ហេតុ និងស្ថានភាព (រួមទាំងលក្ខខណ្ឌអនុវត្ត នៃសក្តានុពលសិទ្ធិបោះឆ្នោត និងកិច្ចសន្យានានាផ្សេងទៀតដោយឡែកឬរួមគ្នា) ដែលអាចប៉ះពាល់ដល់សក្តានុពល សិទ្ធិបោះឆ្នោត លើកលែងតែអ្នកគ្រប់គ្រងមានចេតនា និងលទ្ធភាពហិរញ្ញវត្ថុ ដើម្បីអនុវត្ត ឬបំលែងសិទ្ធិ។

១៦ ក្រុមហ៊ុនបុត្រសម្ព័ន្ធមិនត្រូវបានដកចេញពីការរួមបញ្ចូលគ្នានោះទេ ព្រោះអ្នកវិនិយោគិន គឺជាក្រុមហ៊ុនរួមមូលធន មូលនិធិសង្គហធនសហគ្រាស សម្រាប់ផ្ញើទុកដាក់លុយ និងសហគ្រាស ស្រដៀងគ្នា ។

១៧ ក្រុមហ៊ុនបុត្រសម្ព័ន្ធមិនត្រូវដកចេញពីការរួមបញ្ចូលគ្នានោះទេ ព្រោះសកម្មភាពអាជីវកម្មមិនស្រដៀងទៅនឹងសហគ្រាសដទៃទៀតនៅក្នុងក្រុមឡើយ។ព័ត៌មានពាក់ព័ន្ធទាក់ទិន ត្រូវបានផ្តល់ដោយការរួមបញ្ចូលគ្នានូវក្រុមហ៊ុនបុត្រសម្ព័ន្ធ និងលាតត្រដាងព័ត៌មានបន្ថែមទៀតក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមពីសកម្មភាពអាជីវកម្មផ្សេងគ្នានៃក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ ។ ឧទាហរណ៍ ការលាតត្រដាងព័ត៌មានដែលតម្រូវដោយ ស.រ.ហ.អ.ក៨ ចំឡែកប្រតិបត្តិការពន្យល់ពីភាពខុសគ្នានៃសកម្មភាពអាជីវកម្មផ្សេងគ្នានៅក្នុងក្រុម។

## និតិវិធីនៃការរួមបញ្ចូលគ្នា

១៨ ក្នុងការរៀបចំ របាយការណ៍ហិរញ្ញវត្ថុរួម សហគ្រាស ត្រូវបូកបញ្ចូលគ្នានូវរបាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនមេ និងបុត្រសម្ព័ន្ធទាំងអស់ មួយជួរម្តងៗដោយបូកបញ្ចូលនូវធាតុដែលដូចគ្នានៃទ្រព្យសកម្ម បំណុល ដើមទុន ចំណូល និងចំណាយ ។ ដើម្បីឱ្យរបាយការណ៍ហិរញ្ញវត្ថុរួម បង្ហាញពីព័ត៌មានហិរញ្ញវត្ថុអំពីក្រុមជាសហគ្រាសសេដ្ឋកិច្ចតែមួយ ត្រូវអនុវត្តជំហានបន្តបន្ទាប់ដូចខាងក្រោម÷

(ក) តម្លៃក្នុងបញ្ជីនៃការវិនិយោគរបស់ក្រុមហ៊ុនមេក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនីមួយៗ ហើយចំណែកដើមទុននៃក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន

មេត្រូវបានលុបចោល (សូមមើល ស.រ.ហ.អ.ក ៣ ដែលបរិយាយពីការទទួលស្គាល់នៃការបង្កើតឱ្យមានមូលនិធិពាណិជ្ជកម្ម)។

(ខ) ភាគកម្មអប្បភាគ ក្នុងចំណេញ ឬខាតនៃការរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ពន្ធទាំងអស់សម្រាប់គ្រារាយការណ៍ដែលត្រូវបានកំណត់ និង

(គ) ភាគកម្មអប្បភាគ ក្នុងទ្រព្យសកម្មសុទ្ធនៃការរួមបញ្ចូលក្រុមហ៊ុនបុត្រសម្ពន្ធទាំងអស់ ត្រូវបានកំណត់ដោយឡែកពីភាគកម្មជាកម្មសិទ្ធិរបស់ក្រុមហ៊ុនមេ។ភាគកម្មអប្បភាគក្នុងទ្រព្យសកម្មសុទ្ធ រួមមាន÷

(១) តម្លៃនៃភាគកម្មអប្បភាគនៅថ្ងៃរួមបញ្ចូលគ្នាបានគណនា ស.រ.ហ.អ.ក ៣ និង

(២) បម្រែបម្រួលភាគកម្មអប្បភាគនៅក្នុងមូលធនផ្ទាល់គិតចាប់តាំងពីថ្ងៃនៃការរួមបញ្ចូលគ្នា។

១៩ នៅពេលមានសក្តានុពលសិទ្ធិបោះឆ្នោត ការបែងចែកតាមវិធីសមាមាត្រនៃប្រាក់ចំណេញ ឬ ខាត និងការប្រែប្រួលដើមទុនផ្ទាល់ បានបែងចែកទៅក្នុងក្រុមហ៊ុនមេ និងភាគកម្មអប្បភាគត្រូវបានកំណត់តាមមូលដ្ឋាននៃភាគកម្មជាកម្មសិទ្ធិបច្ចុប្បន្ន និងមិនឆ្លុះបញ្ចាំងពីលទ្ធភាពអនុវត្ត ឬបំលែងនៃមានសក្តានុពលសិទ្ធិបោះឆ្នោតឡើយ ។

**២០ សមតុល្យ ប្រតិបត្តិការ ចំណូល និងចំណាយ នៅក្នុងអង្គភាព ត្រូវបានលុបចោលទាំងអស់ ។**

២១ សមតុល្យ និងប្រតិបត្តិការនៅក្នុងអង្គភាព រួមទាំងចំណូល និងចំណាយ និងភាគលាភ ត្រូវបានលុបចោលទាំងស្រុង។ ចំណេញ និងខាត ដែលបានមកពីប្រតិបត្តិការនៅក្នុងអង្គភាពដែលត្រូវបានទទួលស្គាល់ ក្នុងទ្រព្យសកម្ម ដូចជា សន្និធិ និងទ្រព្យសកម្មអចល័ត ត្រូវបានលុបចោលទាំងស្រុង។ ការខាត

បង់នៅក្នុងអង្គភាព អាចបង្ហាញពីការធ្លាក់ចុះតម្លៃដែលតម្រូវឱ្យទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម។ ស.គ.អ.ក ១២ *ពន្ធលើប្រាក់ចំណេញ* អនុវត្តចំពោះភាពខុសគ្នាជាបណ្តោះអាសន្ន ដែលកើតចេញពីការលុបចោលនូវប្រាក់ចំណេញ និងខាត ដែលបណ្តាលមកពីប្រតិបត្តិការនៅក្នុងអង្គភាព។

២២ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបានរៀបចំឡើង នៅថ្ងៃតែមួយ។ នៅពេលចុងគ្រារាយការណ៍ របស់ក្រុមហ៊ុនមេ ខុសគ្នាពីចុងគ្រារាយការណ៍របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនបុត្រសម្ព័ន្ធ សម្រាប់គោលបំណងរួមបញ្ចូលគ្នា របាយការណ៍ហិរញ្ញវត្ថុបន្ថែម ឱ្យត្រូវគ្នា ត្រូវនឹងថ្ងៃដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ លើកលែងតែមិនអាចអនុវត្តបាន។

២៣ យោងតាមកថាខណ្ឌ ២២ ពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលប្រើនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដែលមានការិយបរិច្ឆេទខុសពីក្រុមហ៊ុនមេ ការកែតម្រូវ ត្រូវធ្វើឡើងសម្រាប់ផលប៉ះពាល់នៃប្រតិបត្តិការ ឬព្រឹត្តិការណ៍ ដែលកើតឡើងរវាងការិយបរិច្ឆេទ និងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ។ ក្នុងករណីខ្លះ ភាពខុសគ្នារវាងចុងគ្រារាយការណ៍របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និងក្រុមហ៊ុនមេ មិនត្រូវឱ្យលើសបីខែឡើយ។ រយៈពេលនៃគ្រារាយការណ៍ និងភាពខុសគ្រារវាងចុងគ្រារាយការណ៍ ត្រូវតែដូចគ្នាពីគ្រាមួយទៅគ្រាមួយទៀត ។

២៤ របាយការណ៍ហិរញ្ញវត្ថុរួម ត្រូវបានរៀបចំឡើងដោយដោយប្រើប្រាស់គោលនយោបាយគណនេយ្យតែមួយ សម្រាប់ប្រតិបត្តិការដូចគ្នា និងព្រឹត្តិការណ៍ក្នុងស្ថានភាពស្រដៀងគ្នា ។

២៥ ប្រសិនបើ សមាជិកនៃក្រុមប្រើប្រាស់គោលនយោបាយគណនេយ្យ ក្រៅពីគោលនយោបាយ ដែលបានប្រើប្រាស់នៅក្នុង របាយការណ៍ហិរញ្ញវត្ថុរួម សម្រាប់ប្រតិបត្តិការ និងព្រឹត្តិការណ៍ក្នុងស្ថានភាពស្រដៀងគ្នា ការកែតម្រូវត្រូវបានធ្វើឡើងលើ របាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដែលត្រូវប្រើប្រាស់ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ។

២៦ ចំណូល និងចំណាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ចាប់ពីថ្ងៃទិញក្រុមហ៊ុនបុត្រសម្ព័ន្ធ ដូចដែលបានកំណត់ក្នុង ស.រ.ហ.អ.ក ៣ ។ ចំណូល និងចំណាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានផ្អែកលើតម្លៃនៃ ទ្រព្យសកម្ម និងបំណុល បានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមនៅថ្ងៃទិញរបស់ក្រុមហ៊ុនមេ។ ឧទាហរណ៍ ចំណាយរំលស់បានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលសរុបរួម បន្ទាប់ពីថ្ងៃទិញត្រូវបានផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្ម ដែលអាចរំលស់បាន ដូចបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមនៅថ្ងៃទិញ ។ ចំណូល និងចំណាយរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានបញ្ចូលក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម រហូតដល់ថ្ងៃដែលក្រុមហ៊ុនមេបញ្ឈប់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

**២៧ ភាគកម្មអប្បភាគ ត្រូវបានបង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុក្នុងផ្នែកដើមទុន ដាច់ដោយឡែកពីដើមទុននៃក្រុមហ៊ុនមេ ។**

២៨ ចំណេញ ឬខាត និងធាតុនីមួយៗនៃចំណូលផ្សេងទៀតត្រូវបានបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងភាគកម្មអប្បភាគ ។ ចំណូលផ្សេងទៀតសរុប គឺត្រូវបែងចែកទៅឱ្យម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនមេនិងភាគកម្មអប្បភាគទោះបីជាលទ្ធផលក្នុងភាគកម្មអប្បភាគមានសមតុល្យអវិជ្ជមានក៏ដោយ ។

២៩ ប្រសិនបើក្រុមហ៊ុនបុត្រសម្ពន្ធ មានភាគហ៊ុនបរិមាប្ដូកបន្តដែលកំពុងធ្វើចរាចរណ៍ដែលត្រូវបានចាត់ថ្នាក់ជាដើមទុន និងកាន់កាប់ដោយភាគកម្មអប្បភាគ ក្រុមហ៊ុនមេគណនាចំណែកចំណេញ ឬខាតរបស់ខ្លួន បន្ទាប់ពីកែតម្រូវភាគលាភលើភាគហ៊ុនទាំងនោះ ទោះជាភាគលាភត្រូវបានប្រកាស ឬមិនប្រកាសក៏ដោយ ។

៣០ **ការផ្លាស់ប្ដូរភាគកម្មជាកម្មសិទ្ធិរបស់ក្រុមហ៊ុនមេ ក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ ដែលមិនមែនជាលទ្ធផល នៃការបាត់បង់ការគ្រប់គ្រង ត្រូវបានចាត់ទុកថាជាប្រតិបត្តិការណ៍ដើមទុន (ឧទាហរណ៍ ប្រតិបត្តិការណ៍ជាមួយម្ចាស់ក្នុងសមត្ថភាពជាម្ចាស់)។**

៣១ ប្រសិនបើផ្លាស់ប្ដូរស្ថានភាពតម្លៃក្នុងបញ្ជីនៃភាគកម្មនៃការគ្រប់គ្រង ឬភាគកម្មអប្បភាគ ត្រូវកែតម្រូវ ដើម្បីឆ្លុះបញ្ចាំងការផ្លាស់ប្ដូរភាគកម្មក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ។ ភាពខុសគ្នារវាងតម្លៃដែលភាគកម្មអប្បភាគត្រូវកែតម្រូវ និងតម្លៃសមស្របនៃតម្លៃតបស្នងដែលបានបង់ ឬទទួល ត្រូវទទួលស្គាល់ដោយផ្ទាល់ក្នុងដើមទុន និងបែងចែកទៅម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនមេ ។

## ការបាត់បង់ការគ្រប់គ្រង

៣២ ក្រុមហ៊ុនមេអាចបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ពន្ធដោយមាន ឬគ្មានការផ្លាស់ប្ដូរដាច់ខាត ឬពាក់ព័ន្ធនឹងកម្រិតកម្មសិទ្ធិ ។ ករណីនេះអាចកើតឡើង ឧទាហរណ៍ នៅពេលក្រុមហ៊ុនបុត្រសម្ពន្ធក្លាយ ទៅជាកម្មវត្ថុនៃការគ្រប់គ្រងរបស់រដ្ឋាភិបាល តុលាការ រដ្ឋបាល ឬអាជ្ញាធរ ។ ករណីនេះក៏អាចកើត ឡើងផងដែរ ដែលជាលទ្ធផលនៃកិច្ចសន្យាព្រមព្រៀង ។

៣៣ ក្រុមហ៊ុនមេ អាចបាត់បង់ការគ្រប់គ្រងក្រុមហ៊ុនបុត្រសម្ព័ន្ធក្នុងប្រតិបត្តិការកិច្ចព្រមព្រៀងមួយ ឬច្រើន។ ប៉ុន្តែ ក្នុងស្ថានភាពខ្លះបង្ហាញថាកិច្ចព្រមព្រៀងជាច្រើនត្រូវបានចាត់ទុកជាប្រតិបត្តិការណ៍តែមួយ។ ក្នុងការកំណត់ពីការចាត់ទុកជា កិច្ចព្រមព្រៀងតែមួយ ក្រុមហ៊ុនមេត្រូវគិតគ្រប់ធាតុ និងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទាំងអស់ និងការប៉ះពាល់សេដ្ឋកិច្ច ។ ការបង្ហាញមួយ ឬច្រើន ខាងក្រោម ដែលក្រុមហ៊ុនមេត្រូវគិតសម្រាប់កិច្ចព្រមព្រៀងច្រើន ដែលចាត់ទុកជាប្រតិបត្តិការណ៍តែមួយ÷

(ក) ត្រូវបានបញ្ចូលក្នុងពេលដូចគ្នា ឬកើតឡើងដើម្បីបំពេញគ្នា។

(ខ) ការបង្កើតប្រតិបត្តិការណ៍តែមួយ ដើម្បីទទួលបានលទ្ធផលពាណិជ្ជ-កម្មទាំងមូល។

(គ) ការកើតឡើងនៃកិច្ចព្រមព្រៀងមួយគឺផ្អែកលើការកើតឡើងយ៉ាងហោចណាស់កិច្ចព្រមព្រៀងមួយទៀត ។

(ឃ) កិច្ចព្រមព្រៀងមួយបានចាត់ទុកថាមានតែមួយ មិនកែតម្រូវនឹងកត្តាសេដ្ឋកិច្ច ប៉ុន្តែនៅពេល មានការកែតម្រូវនឹងកត្តាសេដ្ឋកិច្ចនោះចាត់ទុកថាមានការពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងដទៃទៀត ។ ឧទាហរណ៍ នៅពេលភាគហ៊ុនមួយដែលអាចលក់បាន ត្រូវបានដាក់ថ្លៃក្រោមថ្លៃទីផ្សារ ហើយបន្ទាប់មកត្រូវបានតបស្នងថ្លៃលក់លើថ្លៃទីផ្សារ ។

**៣៤ ប្រសិនបើក្រុមហ៊ុនមេបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ ÷**

(ក) **ឈប់ទទួលស្គាល់ទ្រព្យសកម្ម (រួមទាំង មូលនិធិពាណិជ្ជកម្ម ) និងបំណុលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅតម្លៃក្នុងបញ្ជីនៅថ្ងៃដែលបាត់បង់ការគ្រប់គ្រង**

(ខ) ឈប់ទទួលស្គាល់តម្លៃក្នុងបញ្ជីនៃភាគកម្មអប្បភាគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធចាស់ នៅថ្ងៃដែលបាត់បង់ការគ្រប់គ្រង (រួមទាំងសមាសធាតុនៃចំណេញសរុបដែលបែងចែកទៅភាគកម្មអប្បភាគ)

(គ) ទទួលស្គាល់÷

(១) តម្លៃសមស្របនៃតម្លៃតបស្នងដែលបានទទួល ប្រសិនបើ ពីប្រតិបត្តិការណ៍ ព្រឹត្តិការណ៍ ឬស្ថានភាពដែលជាលទ្ធផលនៃការបាត់បង់ការគ្រប់គ្រង

(២) ប្រសិនបើប្រតិបត្តិការណ៍ដែលជាលទ្ធផលក្នុការបាត់បង់ការគ្រប់គ្រងពាក់ព័ន្ធការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធទៅម្ចាស់ភាគហ៊ុនក្នុងសមត្ថភាពជាម្ចាស់

(ឃ) ទទួលស្គាល់ការវិនិយោគដែលនៅសល់ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធចាស់នៅតម្លៃសមស្របនៅថ្ងៃដែលបាត់បង់ការគ្រប់គ្រង

(ង) ចាត់ថ្នាក់សារជាថ្មីទៅចំណេញ ឬ ខាត ឬ ផ្ទេរដោយផ្ទាល់ទៅប្រាក់ចំណេញរក្សាទុក ប្រសិនបើមានតម្រូវដោយ ស.រ.ហ.អ.ក ដទៃទៀត តម្លៃដែលបានកំណត់ក្នុង កថាខណ្ឌទី ៣៥ និង

(ច) ទទួលស្គាល់លទ្ធផលខុសគ្នាជាចំណេញ ឬខាតក្នុង ចំណេញ ឬខាតដែលអាចបែងចែកទៅក្រុមហ៊ុនមេ។

៣៥ ប្រសិនបើក្រុមហ៊ុនមេបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនមេត្រូវទទួលស្គាល់តម្លៃទាំងអស់ដែលបានទទួលស្គាល់ក្នុងចំណេញសរុបក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនោះផ្អែកលើមូលដ្ឋានដូចគ្នា ដូចក្រុមហ៊ុនមេបានលក់ទ្រព្យសកម្ម ឬបំណុល។ ដូចនេះ បើចំណេញ ឬខាតបានទទួលស្គាល់កាលពីមុនក្នុងចំណេញសរុប ត្រូវតែចាត់ថ្នាក់ជាថ្មីទៅចំណេញ ឬខាតលើការលក់នៃ

ទ្រព្យសកម្ម ឬបំណុល ក្រុមហ៊ុនមេចាត់ថ្នាក់ជាថ្មីការចំណេញ ឬខាតពីដើមទុនទៅចំណេញ ឬខាត (ការកែតម្រូវការចាត់ថ្នាក់ជាថ្មី) នៅពេលបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ។ ឧទាហរណ៍ ប្រសិនបើក្រុមហ៊ុនបុត្រសម្ព័ន្ធមានអត្រាប្តូរប្រាក់បន្តខុសគ្នាពាក់ព័ន្ធប្រតិបត្តិការណ៍បរទេស ហើយក្រុមហ៊ុនមេបាត់បង់ការគ្រប់គ្រងលើ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនមេត្រូវចាត់ថ្នាក់ជាថ្មីទៅចំណេញ ឬខាត ដែលចំណេញ ឬខាតបានទទួលស្គាល់កាលពីមុន ក្នុងចំណេញសរុបពាក់ព័ន្ធនឹងប្រតិបត្តិការណ៍បរទេស ។ ដូចគ្នានេះដែរ អតិរេកវាយតម្លៃឡើងវិញបានទទួលស្គាល់កាលពីមុនក្នុងចំណេញសរុប ត្រូវផ្ទេរដោយផ្ទាល់ទៅចំណេញរក្សាទុកលើការលក់ទ្រព្យសកម្ម ក្រុមហ៊ុនមេ ផ្ទេរអតិរេកវាយតម្លៃឡើងវិញ ដោយផ្ទាល់ទៅចំណេញរក្សាទុកនៅពេលបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ព័ន្ធ ។

៣៦ **ការបាត់បង់ការគ្រប់គ្រងលើ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ការវិនិយោគនៅសល់ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធចាស់ និងតម្លៃដែលកាន់កាប់ដោយ ឬលើក្រុមហ៊ុនបុត្រសម្ព័ន្ធចាស់ត្រូវអនុវត្តតាម ស.រ.ហ.អ.ក ដទៃទៀត ចាប់ពីថ្ងៃដែលបាត់បង់ការគ្រប់គ្រង ។**

៣៧ តម្លៃសមស្របនៃការវិនិយោគនៅសល់ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធចាស់ នៅថ្ងៃដែលបាត់បង់ការគ្រប់គ្រង ត្រូវចាត់ទុកជាតម្លៃសមស្របលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុស្របតាម ស.រ.ហ.អ.ក ៩*ឧបករណ៍ហិរញ្ញវត្ថុ* ឬថ្លៃដើមលើការទទួលស្គាល់ដំបូង នៃការវិនិយោគក្នុងញាតិសម្ព័ន្ធ ឬសហគ្រាសគ្រប់គ្រងរួមគ្នា ។

៣៨ នៅពេលសហគ្រាសរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ត្រូវចាត់ទុកការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា និងញាតិសម្ព័ន្ធទាំង÷

(ក) ថ្លៃដើម ឬ

(ខ) យោងតាម ស.រ.ហ.អ.ក ៩សហគ្រាសត្រូវអនុវត្តគណនេយ្យដូចគ្នាសម្រាប់ការចាត់ថ្នាក់នៃការវិនិយោគ។ ការវិនិយោគបានទទួលស្គាល់នៅថ្លៃដើមត្រូវបានចាត់ទុកស្របតាម ស.រ.ហ.អ.ក ៥ទ្រព្យសកម្មរយៈពេលវែងទុកសម្រាប់លក់ និងប្រតិបត្តិការណ៍មិនបន្តនៅពេលដែលការវិនិយោគ ត្រូវបានចាត់ទុកសម្រាប់លក់ (ឬបានបញ្ចូលក្នុងក្រុមសម្រាប់លក់ដែលត្រូវបានចាត់ថ្នាក់ជាទុកសម្រាប់លក់)។ គណនេយ្យសម្រាប់ការវិនិយោគស្របតាម ស.រ.ហ.អ.ក ៥ មិនត្រូវបានផ្លាស់ប្តូរទេក្នុងស្ថានភាពនេះ។

៣៨ក សហគ្រាស ត្រូវទទួលស្គាល់ភាគលាភពីក្រុមហ៊ុនបុត្រសម្ព័ន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា ឬញាតិសម្ព័ន្ធក្នុងចំណេញ ឬខាត ក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកនៅពេលដែលសហគ្រាសមានសិទ្ធិក្នុងការទទួលភាគលាភ ។

៣៨ខ នៅពេលក្រុមហ៊ុនមេរុះរើចនាសម្ព័ន្ធនៃក្រុមដោយបង្កើតសហគ្រាសថ្មី ដែលក្រុមហ៊ុនមេគោរពបាននូវលក្ខខណ្ឌ ដូចខាងក្រោម ÷

(ក) ក្រុមហ៊ុនមេថ្មីទទួលបានការគ្រប់គ្រងពីក្រុមហ៊ុនមេដើមដំបូង ដោយបោះផ្សាយឧបករណ៍ដើមទុន ក្នុងការដោះដូរឧបករណ៍បច្ចុប្បន្ន នៃក្រុមហ៊ុនមេដើមដំបូង

(ខ) ទ្រព្យសកម្ម និងបំណុលរបស់ក្រុមហ៊ុនមេថ្មី និងក្រុមហ៊ុនមេដើមដំបូង គឺដូចគ្នាមុន និងក្រោយការរុះរើ និង

(គ) ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនមេដើមដំបូងមុនពេលការរុះរើ មានភាគកម្មដូចគ្នាដាច់ខាត និងពាក់ព័ន្ធ ក្នុងទ្រព្យសកម្មសុទ្ធនៃក្រុមដើមដំបូង និងក្រុមថ្មី មុនពេល និងបន្ទាប់ ការរុះរើ ហើយក្រុមហ៊ុនមេថ្មីទទួលស្គាល់សម្រាប់ការវិនិយោគរបស់ខ្លួនក្នុងក្រុមហ៊ុនមេដើមដំបូង ស្របតាមកថាខណ្ឌទី ៣៨ (ក) ក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ក្រុមហ៊ុនមេថ្មីវាស់វែងថ្លៃដើមនៅតម្លៃក្នុងបញ្ជីនៃធាតុដើមទុនបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកនៃក្រុមហ៊ុនមេដើមដំបូងនៅថ្ងៃរុះរើ។

៣៨គ ស្រដៀងគ្នា សហគ្រាសដែលមិនមែនជាក្រុមហ៊ុនមេបង្កើតសហគ្រាសថ្មីដែលក្រុមហ៊ុនមេអាចគោរពបានក្នុងលក្ខខណ្ឌក្នុងកថាខណ្ឌទី ៣៨ខ ។ លក្ខខណ្ឌតម្រូវក្នុងកថាខណ្ឌទី៣៨ខ អនុវត្តស្មើគ្នាដូចការរុះរើដែរ ។ ក្នុងករណីនេះ យោងទៅលើក្រុមហ៊ុនមេដើមដំបូង និងក្រុមដើមដំបូង គឺទៅសហគ្រាសដើមដំបូង។

៣៩ ស្តង់ដារនេះមិនតម្រូវដាច់ខាតចំពោះសហគ្រាស ដែលរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែកសម្រាប់សាធារណជនប្រើប្រាស់ទេ ។ កថាខណ្ឌទី ៣៨ និង ៤០-៤៣ អនុវត្តនៅពេលសហគ្រាសមួយ រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែកដែលអនុវត្តតាម ស.រ.ហ.អ.ក ។ សហគ្រាសក៏រៀបចំរបាយ

ការណ៍ហិរញ្ញវត្ថុរួម សម្រាប់សាធារណជនប្រើប្រាស់ ដូចបានតម្រូវក្នុងកថាខណ្ឌទី៩ លើកលែងតែមានការលើកលែងដូចបានផ្តល់ក្នុងកថាខណ្ឌទី ១០។

៤០ ការវិនិយោគក្នុងសហគ្រាសគ្រប់គ្រងរួមគ្នា និងញាតិសម្ពន្ធដែលត្រូវបាទទួលស្គាល់ស្របតាម ស.រ.ហ.អ.ក ៩ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ត្រូវទទួលស្គាល់ដូចគ្នាទៅនឹងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់វិនិយោគិន ។

## ការលាតត្រដាងព័ត៌មាន

---

៤១ ការលាតត្រដាងបង្ហាញខាងក្រោម ត្រូវធ្វើឡើងសម្រាប់របាយការណ៍ហិរញ្ញវត្ថុរួម៖

(ក) ទំនាក់ទំនងរវាងក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ពន្ធ នៅពេលដែលក្រុមហ៊ុនមេមិនកាន់កាប់ ដោយផ្ទាល់ ឬប្រយោល ទៅលើក្រុមហ៊ុនបុត្រសម្ពន្ធតាមអំណាចបោះឆ្នោតច្រើនជាងពាក់កណ្តាល

(ខ) មូលហេតុកម្មសិទ្ធិលើក្រុមហ៊ុនបុត្រសម្ពន្ធដោយផ្ទាល់ឬប្រយោល ដែលមានអំណាចបោះឆ្នោតលើសពីពាក់កណ្តាល ឬសក្តានុពលសិទ្ធិបោះឆ្នោត របស់អ្នកទទួលបានការវិនិយោគ ដែលមិនមានសិទ្ធិគ្រប់គ្រង

(គ) នៅចុងគ្រារាយការណ៍ នៃរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនបុត្រសម្ពន្ធ ដែលរបាយការណ៍ហិរញ្ញវត្ថុនោះ ត្រូវបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម និងត្រូវបានកំណត់ទុកជាថ្ងៃរាយការណ៍ ឬសម្រាប់គ្រា ដែលខុសគ្នាពីគ្រារាយការណ៍ នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមេ និងមូលហេតុក្នុងប្រើថ្ងៃ ឬគ្រាខុសគ្នា និង

(ឃ) លក្ខណៈនិងវិសាលភាពនៃការដាក់កំហិតផ្សេងៗ (ឧទាហរណ៍÷ កើតចេញពីកិច្ចព្រមព្រៀងកម្ចី ឬលក្ខខណ្ឌបទប្បញ្ញត្តិ ) លើលទ្ធភាពរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដើម្បីផ្ទេរមូលនិធិឱ្យក្រុមហ៊ុនមេ ក្នុងទម្រង់ជាភាគលាភជាសាច់ប្រាក់ ឬសងបំណុល ឬ ការធ្វើបុរេប្រទាន

(ង) តារាងដែលបង្ហាញថា ផលប៉ះពាល់នៃការផ្លាស់ប្តូរភាគកម្មជាកម្មសិទ្ធិរបស់ក្រុមហ៊ុនមេក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ មិនបានបាត់បង់កាគ្រប់គ្រងលើដើមទុនដែលអាចបែងចែកទៅម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនមេ និង

(ច) ប្រសិនបើ ការគ្រប់គ្រងក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានបាត់បង់ ក្រុមហ៊ុនមេត្រូវលាតត្រដាងព័ត៌មានចំណេញ ឬខាត ប្រសិនបើមាន បានទទួលស្គាល់ស្របតាមកថាខណ្ឌទី ៣៤ និងត្រូវ÷

(១) ចំណែកនៃចំណេញ ឬ ខាតអាចបែងចែកទៅក្នុងការវិនិយោគនៅសល់ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅតម្លៃសមស្របនៅថ្ងៃដែលការគ្រប់គ្រងបាត់បង់ និង

(២) ធាតុនៅក្នុងរបាយការណ៍លទ្ធផលសរុបដែលចំណេញ ឬខាតត្រូវទទួលស្គាល់ (ប្រសិនបើមិនបានបង្ហាញដាច់ដោយឡែកក្នុងរបាយការណ៍លទ្ធផលសរុប) ។

៤២ នៅពេលរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ត្រូវបានរៀបចំឡើងសម្រាប់ក្រុមហ៊ុនមេ ស្របតាមកថាខណ្ឌ ១០ ដោយជ្រើសរើសមិនរៀបចំរបាយការណ៍-ហិរញ្ញវត្ថុរួម របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ត្រូវតែលាតត្រដាងព័ត៌មានដូចខាងក្រោម÷

(ក) ហេតុដែលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំជារបាយការណ៍ហិរញ្ញវត្ថុដោយឡែក ដែលលើកលែងពីការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

ត្រូវបានប្រើ រួមមាន ឈ្មោះ និង ប្រទេសដែលបង្កើត ឬទីតាំងនៃសហគ្រាសដែលរបាយការណ៍នៃហិរញ្ញវត្ថុរួម ត្រូវអនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដែលត្រូវបានបោះផ្សាយសម្រាប់សាធារណជនប្រើប្រាស់ និងអាសយដ្ឋានដែលអាចទទួលបានរបាយការណ៍ហិរញ្ញវត្ថុរួមនោះ

(ខ) បញ្ជីនៃការវិនិយោគសំខាន់ៗនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា និងញាតិសម្ព័ន្ធរួមមានឈ្មោះ និងប្រទេសដែលបង្កើត ឬទីតាំងនៃ ប្រសិនបើខុសគ្នា ចំណែកភាគកម្មជាកម្មសិទ្ធិ និងចំណែកនៃអំណាចបោះឆ្នោត ដែលកាន់កាប់ និង

(គ) បរិយាយពីវិធីសាស្ត្រដែលបានប្រើ ដើម្បីទទួលស្គាល់ការវិនិយោគដូចមានក្នុង ចំនុច (ខ) ។

៤៣ នៅពេលក្រុមហ៊ុនមេ (មិនមែនក្រុមហ៊ុនមេដែលមានក្នុងកថាខណ្ឌ ៤២) អ្នកដាក់ទុនរួមគ្នាជា ភាគកម្មក្នុងសហគ្រាសគ្រប់គ្រងរួមគ្នា និងវិនិយោគិនក្នុងញាតិសម្ព័ន្ធ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែក ហើយត្រូវលាតត្រដាងព័ត៌មាន ដូចខាងក្រោម÷

(ក) ហេតុដែលត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយឡែក និងមូលហេតុដែលរបាយការណ៍ហិរញ្ញវត្ថុនោះត្រូវបានរៀបចំឡើង ប្រសិនបើមិនតម្រូវដោយច្បាប់ទេ

(ខ) បញ្ជីនៃការវិនិយោគសំខាន់ៗ នៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា និង ញាតិសម្ព័ន្ធ រួមមានឈ្មោះ និងប្រទេសដែលបង្កើត ឬទីតាំងចំណែកនៃភាគកម្មជាកម្មសិទ្ធិ និង ប្រសិនបើខុសគ្នា និងចំណែកនៃអំណាចបោះឆ្នោតដែលកាន់កាប់ និង

(គ) **រៀបរាប់ពីវិធីសាស្ត្រដែលប្រើ ដើម្បីទទួលស្គាល់ការវិនិយោគដូចមានក្នុង ចំនុច (ខ) និង ត្រូវបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងស្របតាមកថាខណ្ឌ ៩ នៃស្តង់ដារនេះឬ ស.គ.អ.ក ២៨ និង ស.គ.អ.ក ៣១ ដែលពាក់ព័ន្ធ ។**

## ថ្ងៃចូលជាធរមាន និងអន្តរកាល

៤៤ សហគ្រាសត្រូវអនុវត្តស្តង់ដារនេះ សម្រាប់គ្រាចាប់ផ្តើមពី ឬបន្ទាប់ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៥។ ការអនុវត្តមុនត្រូវបានលើកទឹកចិត្ត។ ប្រសិនបើសហគ្រាសអនុវត្តស្តង់ដារនេះ មុនថ្ងៃទី ១ ខែមករា ឆ្នាំ២០០៥ សហគ្រាសនោះត្រូវលាតត្រដាងព័ត៌មានពីហេតុ ។

៤៥ សហគ្រាសត្រូវអនុវត្តការធ្វើវិសោធនកម្មទៅ ស.គ.អ.ក ២៧ ក្នុងឆ្នាំ ២០០៨ ក្នុងកថាខណ្ឌទី ៤ ១៨ ១៩ ២៦-៣៧ និង៤១(ង) និង(ច) សម្រាប់គ្រាចាប់ផ្តើមពី ឬបន្ទាប់ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាត។ ប៉ុន្តែ សហគ្រាសមិនត្រូវអនុវត្តការធ្វើវិសោធនកម្មទាំងនេះ សម្រាប់គ្រាចាប់ផ្តើមមុន ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩ លើកលែងតែមានការអនុវត្ត ស.រ.ហ.អ.ក ៣ ដែរ (ដូចបានកែសម្រួលក្នុង ឆ្នាំ ២០០៨) ។ ប្រសិនបើ សហគ្រាសអនុវត្តសម្រាប់គ្រាចាប់ផ្តើមមុន ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៩ ត្រូវលាតត្រដាងព័ត៌មានពីហេតុ។ សហគ្រាសត្រូវអនុវត្តការធ្វើវិសោធនកម្មត្រឡប់ក្រោយ លើកលែងករណីដូចខាងក្រោម÷

(ក) ការធ្វើវិសោធនកម្មទៅកថាខណ្ឌទី២៨ សម្រាប់បែងចែងទៅចំណេញសរុបទៅម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនមេ និងទៅភាគកម្មអប្បភាគ បើ

ទោះបីជាលទ្ធផលនេះ នាំឱ្យភាគកម្មអប្បភាគមានសមតុល្យឱនភាព ក៏ដោយ។ ដូចនេះ សហគ្រាសមិនត្រូវបង្ហាញឡើងវិញនូវចំណេញ ឬខាត បែងចែក សម្រាប់គ្រារាយការណ៍មុនពេលការធ្វើវិសោធនកម្ម ត្រូវបានអនុវត្ត ។

(ខ) លក្ខខណ្ឌក្នុងកថាខណ្ឌទី ៣០ និង៣១ សម្រាប់គណនេយ្យក្នុងការផ្លាស់ប្តូរភាគកម្មជាកម្មសិទ្ធិក្នុងក្រុមហ៊ុនមេបន្ទាប់ទទួលបានការគ្រប់គ្រង។ ដូចនេះ លក្ខខណ្ឌក្នុងកថាខណ្ឌទី ៣០ និង ៣១ មិនអនុវត្តចំពោះការផ្លាស់ប្តូរដែលបានកើតឡើងមុនពេលសហគ្រាសអនុវត្តការធ្វើវិសោធនកម្ម ។

(គ) លក្ខខណ្ឌក្នុងកថាខណ្ឌទី៣៤-៣៧ សម្រាប់ការបាត់បង់ការគ្រប់គ្រងក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ។ សហគ្រាសមិនត្រូវបង្ហាញឡើងវិញនូវតម្លៃក្នុងបញ្ជីនៃការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ពន្ធមុន ប្រសិនបើការគ្រប់គ្រងត្រូវបានបាត់បង់មុនពេលសហគ្រាសអនុវត្ត ការធ្វើវិសោធនកម្ម។ បន្ថែមពីនេះ សហគ្រាសមិនត្រូវគណនាឡើងវិញ នូវចំណេញ ឬខាតលើការបាត់បង់ការគ្រប់គ្រងលើក្រុមហ៊ុនបុត្រសម្ពន្ធមុនដែលបានកើតឡើងមុនពេល ការអនុវត្តការធ្វើវិសោធនកម្ម។

៤៥ក កថាខណ្ឌទី ៣៨ ត្រូវបានធ្វើវិសោធនកម្មដោយបសិដ្ឋកម្មទៅ ស.រ.ហ.អ.ក បានបោះផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨។ សហគ្រាសត្រូវអនុវត្តការធ្វើវិសោធនកម្មនោះសម្រាប់គ្រាចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៩ ទៅមុខ ចាប់ពីថ្ងៃដែលអនុវត្ត ស.រ.ហ.អ.ក ៥ ដំបូង។ ការអនុវត្តមុនត្រូវបានអនុញ្ញាត។ ប្រសិនបើសហគ្រាសអនុវត្តការធ្វើវិសោធនកម្មសម្រាប់គ្រាមុន ត្រូវលាតត្រដាងព័ត៌មានពីហេតុនោះ។

៤៥ខ ថ្លៃដើមនៃការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា ឬ ញាតិសម្ពន្ធ (ការធ្វើវិសោធនកម្ម ទៅ ស.រ.ហ.អ.ក ១ និង ស.គ.អ.ក ២៧) បានបោះផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨ លុបចោលនិយមន័យនៃវិធីសាស្រ្ត ថ្លៃដើមពីកថាខណ្ឌទី ៤ និងបន្ថែមក្នុង កថាខណ្ឌទី ៣៨ ក។ សហគ្រាសត្រូវ អនុវត្តការធ្វើវិសោធនកម្មទាំងនោះទៅមុខសម្រាប់គ្រាចាប់ផ្តើមនៅ ឬបន្ទាប់ ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩។ ការអនុវត្តមុនត្រូវបានអនុញ្ញាត។ ប្រសិនបើ សហគ្រាស អនុវត្តការផ្លាស់ប្តូរសម្រាប់គ្រាមុន សហគ្រាសត្រូវលាតត្រដាង ព័ត៌មានពីហេតុ និងអនុវត្តការធ្វើវិសោធនកម្មដែលពាក់ព័ន្ធទៅ ស.គ.អ.ក ១៨ ស.គ.អ.ក ២១ និង ស.គ.អ.ក ៣៦ នៅគ្រាដូចគ្នា ។

៤៥គ ថ្លៃដើមនៃការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ពន្ធ សហគ្រាសគ្រប់គ្រងរួមគ្នា ឬ ញាតិសម្ពន្ធ (ការធ្វើវិសោធនកម្ម ទៅ ស.រ.ហ.អ.ក ១ និង ស.គ.អ.ក ២៧) បានបោះផ្សាយក្នុងខែឧសភា ឆ្នាំ២០០៨ បានបន្ថែមកថាខណ្ឌទី ៣៨ខ និង ៣៨គ។ សហគ្រាសត្រូវអនុវត្តកថាខណ្ឌទាំងនោះទៅមុខ ទៅលើការរុះរើ កើតឡើងក្នុងគ្រាចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី០១ ខែ មករា ឆ្នាំ២០០៩។ ការ អនុវត្តមុនត្រូវបានអនុញ្ញាត។ បន្ថែមពីនេះ សហគ្រាសអាចជ្រើសរើសការ អនុវត្តកថាខណ្ឌទី ៣៨ ខ និង ៣៨ គ ត្រឡប់ក្រោយទៅលើការរុះរើអតីត កាលក្នុងវិសាលភាព នៃកថាខណ្ឌទាំងនេះ។ ប៉ុន្តែ ប្រសិនបើសហគ្រាស បង្ហាញឡើងវិញការរុះរើណាមួយ ដើម្បីអនុវត្តតាមកថាខណ្ឌទី ៣៨ ខ ឬ ៣៨ គ សហគ្រាសត្រូវបង្ហាញឡើងវិញគ្រប់ការរុះរើទាំងអស់បន្ទាប់ ស្រប តាមវិសាលភាពនៃ កថាខណ្ឌទាំងនោះ ។ ប្រសិនបើសហគ្រាសអនុវត្តកថា ខណ្ឌទី ៣៨ ខ ឬ ៣៨ គ សម្រាប់គ្រាមុន ត្រូវលាតត្រដាងព័ត៌មាន ។

៤៥ឃ លុបចោល

៤៥ង ស.រ.ហ.អ.ក បានបោះផ្សាយក្នុងខែតុលា ឆ្នាំ ២០១០ បានធ្វើវិសោធនកម្ម កថាខណ្ឌទី ៣៥ ៣៧ និង ៤០ និងបានលុបចោល កថាខណ្ឌទី ៤៥ ឃ។ សហគ្រាសត្រូវអនុវត្តការធ្វើវិសោធនកម្មទាំងនោះ នៅពេលសហគ្រាសអនុវត្ត ស.រ.ហ.អ.ក ៩ បានបោះផ្សាយក្នុងខែតុលា ឆ្នាំ២០១០ ។

## ការដកចេញនៃ ស.គ.អ.ក ២៧ (២០០៣)

៤៦ ស្តង់ដារនេះត្រូវធ្វើជំនួសឱ្យ ស.គ.ក ២៧ *របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក(ដូចបានកែសម្រួលក្នុងឆ្នាំ២០០៣)* ។

**ក្រុមប្រឹក្សាជាតិគណនេយ្យ**
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាសយដ្ឋាន៖ ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល៖ info@naccambodia.gov.kh | គេហទំព័រ៖ www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ